**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៦៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.អ.ទ.** ដើម្បីដឹកនាំជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា។

## ជំពូកទី២
## សមាសភាពនៃ គ.ជ.អ.ទ.

**មាត្រា២ .-**

សមាសភាពនៃ **គ.ជ.អ.ទ.** មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ឧបនាយករដ្ឋមន្ត្រី ១រូប | ប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៤- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | អនុប្រធាន |
| ៥- | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៧- | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤- | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៥- | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៦- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ១៧- | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៨- | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ២០- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| ២១- | រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| ២២- | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| ២៣- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ២៤- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| ២៥- | រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ២៦- | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៧- | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៨- | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ២៩- | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៣០- | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៣១- | តំណាងក្រសួងទេសចរណ៍ ៨រូប | សមាជិក |
| ៣២- | ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ជ.អ.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.អ.ទ.

**មាត្រា៣ .-**

**គ.ជ.អ.ទ.** ជាសេនាធិការជូនរាជរដ្ឋាភិបាលដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល សហការ និងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជា
- សម្របសម្រួលនិងជំរុញការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ និង បទប្បញ្ញត្តិនានា សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍
- សម្របសម្រួលនិងជំរុញលើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីវិស័យទេសចរណ៍ ពិសេស ផលប៉ះពាល់នៃវិស័យនេះទៅលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- លើកគំនិតផ្តួចផ្តើមនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលអំពីទស្សនាទាន ជម្រើសគោលនយោបាយ ការកែទម្រង់ ការកំណត់ទិសដៅ គោលដៅ ចក្ខុវិស័យនៃការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ ឱ្យកាន់តែមានប្រសិទ្ធភាព
- ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍
- តាមដាន ត្រួតពិនិត្យ វាយតម្លៃសភាពការណ៍ពាក់ព័ន្ធនឹងវិស័យទេសចរណ៍ និងរៀបចំរបាយការណ៍បូកសរុបការងារអនុវត្ត ស្ថានភាពទេសចរណ៍ លើកយោបល់ឬដំណោះស្រាយ ព្រមទាំងវិធានការនានាជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេច
- ពិនិត្យ អនុម័ត និងគ្រប់គ្រងគម្រោងផែនការសកម្មភាពរបស់ **គ.ជ.អ.ទ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយរាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ គ.ជ.អ.ទ.

**មាត្រា៤ .-**

ប្រធាន **គ.ជ.អ.ទ.** ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់រៀងរាល់ដំណាច់ឆមាសនីមួយៗ។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានណាមួយដែលបានទទួលសិទ្ធិពីប្រធាន ត្រូវដឹកនាំការប្រជុំរបស់ **គ.ជ.អ.ទ.**។

**មាត្រា៥ .-**

ប្រធាន **គ.ជ.អ.ទ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់ការងារទាំងឡាយដែលទាក់ទងនឹង **គ.ជ.អ.ទ.**។

**មាត្រា៦ .-**

**គ.ជ.អ.ទ.** មានសិទ្ធិបង្កើតគណៈកម្មការអន្តរក្រសួងតាមការចាំបាច់ ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍវិស័យទេសចរណ៍ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

**គ.ជ.អ.ទ.** ត្រូវបង្កើតគណៈកម្មាធិការអភិវឌ្ឍទេសចរណ៍រាជធានី ខេត្ត ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

**មាត្រា៧ .-**

**គ.ជ.អ.ទ.** មាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៃក្រសួងទេសចរណ៍ជាលេខាធិការដ្ឋាន។

ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៃក្រសួងទេសចរណ៍ជាប្រធានលេខាធិការដ្ឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

ប្រធានលេខាធិការដ្ឋានមានសិទ្ធិប្រើប្រាស់មន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ក្នុងការបំពេញភារកិច្ច។

**មាត្រា៨ .-**

**គ.ជ.អ.ទ.** មានត្រាដោយឡែករបស់ខ្លួន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ជ.អ.ទ.

**មាត្រា៩ .-**

ការចំណាយសម្រាប់កិច្ចដំណើរការ **គ.ជ.អ.ទ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងទេសចរណ៍។

**គ.ជ.អ.ទ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមនីតិវិធីច្បាប់ជាធរមាន សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១០ .-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការតែងតាំងនិងការបង្កើតយន្តការនានាក្រោមចំណុះសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទេសចរណ៍ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៧០ សសរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៦៨ អនក្រ.បក
ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៩